# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត ពិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ២៤ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងសេចក្តីអនុម័តទុកចិត្តរបស់រដ្ឋសភាលើសមាសភាព នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៩៣
- យោងតាមការចាំបាច់

## ក្រាស់បង្គាប់

**មាត្រា១ :** ការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ

រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋានទទួលខុសត្រូវ ក្នុងការដឹកនាំគ្រប់គ្រងធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធ តំបន់ការពារធម្មជាតិរបស់ជាតិ រួមមានការការពារបរិដ្ឋាន ដី ព្រៃឈើ តំបន់ដីសើម និងតំបន់ឆ្នេរ ។ រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋានមានសិទ្ធិអំណាចបង្កើត និងធ្វើជាប្រធានគណៈកម្មាធិការសមស្រប សំរាប់សំរបសំរួលអន្តរក្រសួងលើបន្ទាត់នយោបាយ និងបច្ចេកទេស ។ ការគ្រប់គ្រងនិងអភិបាលប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ ជាការទទួលខុសត្រូវរួមរបស់រដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន ដោយសហការជាមួយស្ថាប័នមានសមត្ថកិច្ចឯទៀត ។

ប្រព័ន្ធនេះរួមបញ្ចូលរាល់ប្រភេទដែនបំរុងទុកសំរាប់ទិសដៅគ្រប់គ្រងដូចតទៅ ÷

១ - *ឧទ្យានធម្មជាតិ* : ដែនធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារ ដើម្បីបំរើអោយវិទ្យាសាស្ត្រ អប់រំ និងការកំសាន្ត ។

*២ - ដែនជំរកសត្វព្រៃ :* ដែនធម្មជាតិដែលបានានូវលក្ខខ័ណ្ឌធម្មជាតិ ចាំបាច់ក្នុងការការពារប្រភេទសត្វព្រៃ និងរុក្ខជាតិរបស់ជាតិសំខាន់ៗ និងសហគមន៍ធម្មជាតិ ឬលក្ខណៈរូបសាស្រ្តរបស់បរិដ្ឋាន ជាទីដែលភាវៈទាំងនេះ ត្រូវការ ជាពិសេសនូវអន្តរាគមន៍ពីមនុស្ស សំរាប់ភាពស្ថិតស្ថេររបស់វា ។

*៣ - តំបន់ការពារទេសភាព :* តំបន់ដែលត្រូវថែទាំទេសភាពធម្មជាតិ និងពាក់កណ្តាលធម្មជាតិសំខាន់ៗ សំរាប់រមណីយស្ថានដល់សាធារណៈជនក្នុងការសំរាកកំសាន្ត និងធ្វើទេសចរណ៍ ។

*៤ - តំបន់ដែលទទួលរងនូវការប្រើប្រាស់ច្រើនមុខ :* តំបន់ដែលផ្តល់នូវភាពស្ថិតស្ថេរលើប្រភពទឹក ព្រៃឈើ សត្វព្រៃ ត្រី វាលស្មៅ និងការកំសាន្តដែលត្រូវអោយមានការអភិវឌ្ឍន៍អភិរក្សធម្មជាតិក្នុងគោលដៅចំបងនៃសកម្មភាពសេដ្ឋកិច្ច ។

**មាត្រា២ :** ការកំណត់តំបន់ការពារធម្មជាតិ

ការកំណត់ប្រព័ន្ធអេឡូស៊ី ដី តំបន់ដីសើម និងតំបន់ឆ្នេរសមុទ្រ ត្រូវបានបញ្ជាក់នៅក្នុងផែនទី ដែលភ្ជាប់ជាមួយនេះ ដើម្បីចាត់ចែងនិងអភិវឌ្ឍន៍តាមការកំណត់ដូចតទៅ ÷

**១ - ឧទ្យានជាតិ :**

| | ផ្ទៃដី « ហ.ត » | ទីតាំង |
|---|---|---|
| ១- ខ្នងរាបគីរីរម្យ | ៣៥.០០០ | ខេត្តកំពង់ស្ពឺនិងកោះកុង |
| ២- ភ្នំបូកគោ | ១៤០.០០០ | ខេត្តកំពត |
| ៣- កែប | ៥.០០០ | ខេត្តកំពត |
| ៤- រាម | ១៥០.០០០ | ក្រុងព្រះសីហនុ |
| ៥- បុទុមសាគរ | ១៧១.២៥០ | ខេត្តកោះកុង |
| ៦- ភ្នំគូលេន | ៣៧.៥០០ | ខេត្ត សៀមរាប |
| ៧- វីរៈជ័យ | ៣៣២.៥០០ | ខេត្តស្ទឹងត្រែង និងរតនគិរី |

**២ - ដែនជំរកសត្វព្រៃ**

| | | |
|---|---|---|
| ៨- ភ្នំឱរ៉ាល់ | ២៥៣.៧៥០ | ខេត្តកោះកុង , ពោធិសាត់, កំពង់ស្ពឺ |
| ៩- ពាមក្រសោប | ២៣.៧៥០ | ខេត្ត កោះកុង |
| ១០- ភ្នំសំកុស | ៣៣៣.៧៥០ | ខេត្ត កោះកុង |
| ១១- រនាមដូនសំ | ១៧៨.៧៥០ | ខេត្ត បាត់ដំបង |

| | | |
|---|---|---|
| ១២- គូលេន-ព្រហ្មទេព | ៤០២.៥០០ | ខេត្ត សៀមរាបនិងព្រះវិហារ |
| ១៣- បឹងពែរ | ២៤២.៥០០ | ខេត្ត កំពង់ធំ |
| ១៤- លំផាត់ | ២៥០.០០០ | ខេត្ត រតនគិរី និងមណ្ឌលគិរី |
| ១៥- ភ្នំព្រេច | ២២២.៥០០ | ខេត្តមណ្ឌលគិរី និងក្រចេះ |
| ១៦- ភ្នំណាមលៀរ | ៤៧.៥០០ | ខេត្តមណ្ឌលគិរី |
| ១៧- ស្នួល | ៧៥.០០០ | ខេត្តក្រចេះ |

<u>៣ - តំបន់ការពារទេសភាព</u>

| | | |
|---|---|---|
| ១៨- អង្គរ | ១០.៨០០ | ខេត្ត សៀមរាប |
| ១៩- បន្ទាយឆ្មារ | ៨១.២០០ | ខេត្ត បន្ទាយមានជ័យ |
| ២០- ព្រះវិហារ | ៥.០០០ | ខេត្ត ព្រះវិហារ |

<u>៤ - តំបន់ប្រើប្រាស់ច្រើនយ៉ាង</u>

| | | |
|---|---|---|
| ២១- ដងពែង | ២៧.៧០០ | ខេត្ត កោះកុង |
| ២២- សំឡូត | ៦០.០០០ | ខេត្តបាត់ដំបង |
| ២៣- ទន្លេសាប | ៣១៦.២៥០ | ខេត្តកំពង់ឆ្នាំង ,កំពង់ធំ,សៀមរាប, បាត់ដំបង,និងពោធិសាត់ |

**មាត្រា៣ :** វិសោធនកម្ម

បណ្តាប្រព័ន្ធការពារធម្មជាតិនេះ អាចនឹងកែប្រែពង្រីកបន្ថែមនៅពេលអនាគត ដោយផ្អែកលើពត៌មានវិទ្យាសាស្ត្រជាមូលដ្ឋាន ដែលទាក់ទងទៅនឹងអភិរក្សជីវសាស្ត្រ និងការរក្សាអោយមានភាពស្ថិតស្ថេរនៃទេសភាពនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ :** អាទិភាព

បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋលេខាធិការគ្រប់គ្រងការពារបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា៦ :** ការអនុវត្តន៍

ក្រឹត្យនេះ មានអនុភាពជាតតិយុត្តិទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃ ឡាយព្រះហស្ថលេខាតទៅ ។

*ធ្វើនៅភ្នំពេញ ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣*

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

**********

ព្រំប្រទល់ដែននៃតំបន់ការពារធម្មជាតិនីមួយៗ

មាត្រដ្ឋាន = ១ : ៥០០ ០០០

ផ្លូវ = ពណ៌ក្រហម

ផ្លូវទឹក = ពណ៌ខៀវ

ព្រំប្រទល់ដែនប្រទេស : ពណ៌ខ្មៅ

ខ្សែកាត់ត្រង់ពីចំណុចមួយទៅចំណុចមួយទៀត = ពណ៌បៃតង

យោងតាមផែនទី "Cambodia Briefing Map" ដែលត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់ អគ្គសេនាធិការនៃកងទ័ពអូស្ត្រាលី ដោយអង្គភាពស្ទង់នៃរាជាណាចក្រអូស្ត្រាលី,Commonweath of Australia នាឆ្នាំ ១៩៩២ ។

# ការជ្រើសរើសតំបន់សំរាប់ការពារធម្មជាតិ



១. ឧទ្យានជាតិ ខ្ពង់រាបគិរីរម្យ




២. ឧទ្យានជាតិ ភ្នំបូកគោ









៥. ឧទ្យានជាតិ បុទុមសាគរ




៦. ឧទ្យានជាតិ ភ្នំគូលេន



៧. ឧទ្យានជាតិ វីរៈជ័យ



៨. ដែនជំរកសត្វព្រៃ ភ្នំឱរ៉ាល់



## ៩. ដែនជំរកសត្វព្រៃ ពាមក្រសោប



## ១០. ដែនជំរកសត្វព្រៃ ភ្នំសំកុស



១១. ដែនជំរកសត្វព្រៃ រនាមដូនសំ




WARNING
Unlisted radio emissions from this area may constitute a navigation hazard
CHOAM KHSANT
PHUM KULEN
28
23
26

១៣. ដែនជំរកសត្វព្រៃ បឹងពែរ



១៩. ដែនជំរកសត្វព្រៃ លំផាត់



១៥. ដែនជំរកសត្វព្រៃ ភ្នំព្រេច



១៦. ដែនជំរកសត្វព្រៃ ភ្នំណាមលៀរ



១៧. ដែនជំរកសត្វព្រៃ ស្នួល




១៨. តំបន់ការពារទេសភាព អង្គរ



... តំបន់ការពារទេសភាព ជន្លាយស្គារ




២០. តំបន់ការពារទេសភាព ព្រះវិហារ



២១. តំបន់ប្រើប្រាស់ច្រើនយ៉ាង ដងពែង




២២. តំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត






PARC D'ANGKOR
ANNEXE IV